**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ធនាគារជាតិ នៃ កម្ពុជា

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# សេចក្តីប្រកាសព័ត៌មានរួម

## ស្តីពី

## ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី" រវាង ធនាគារជាតិនៃកម្ពុជា និង ក្រសួងកិច្ចការនារី

នារសៀលថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្តីពី "ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី" នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងលោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី។

អនុស្សរណៈយោគយល់នេះ មានគោលបំណងបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការ ដែលមានរយៈពេលអនុវត្តន៍ ៥ឆ្នាំ សំដៅលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី តាមរយៈការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងហិរញ្ញវត្ថុឌីជីថល ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច និងការពង្រីកភាពជាដៃគូក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី។ អនុស្សរណៈយោគយល់នេះក៏នឹងអនុញ្ញាតឱ្យភាគីទាំងពីរ បន្តចូលរួមសម្រេចគោលដៅកំណត់ក្នុងយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨ ផងដែរ។

លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានមានប្រសាសន៍ថា៖ "ការជួយឱ្យស្ត្រីទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដែលមានកិច្ចការពារតាមផ្លូវច្បាប់ ពិតជាមានសារៈសំខាន់ដល់ការជំរុញកំណើនសេដ្ឋកិច្ច ក៏ដូចជាកាត់បន្ថយវិសមភាពនិងភាពក្រីក្រសម្រាប់ស្ត្រីដែលមានចំណូលទាប និងស្ត្រីនៅតាមតំបន់ជនបទ ហើយថែមទាំងអាចគាំទ្រសកម្មភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទៀតផង។ អនុស្សរណៈនៃការយោគយល់នេះ គឺជាសក្ខីភាពដែលបង្ហាញពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការរវាង ធនាគារជាតិនៃកម្ពុជា និង ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូនៃសកម្មភាពបន្តលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ប្រកបដោយប្រសិទ្ធភាព។"

លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី បានវាយតម្លៃខ្ពស់ចំពោះភាពជាដៃគូរវាងស្ថាប័នទាំងពីរ និងកិច្ចសហប្រតិបត្តិការដ៏ល្អ ទាំងបច្ចេកទេសរវាងក្រុមការងារនៃស្ថាប័នទាំងពីរ និងការគាំទ្រពីថ្នាក់ដឹកនាំ ធនាគារជាតិនៃកម្ពុជា ក្រោមការណែនាំពីលោកជំទាវ ទេសាភិបាល។ ភាពជាដៃគូ

ក្នុងការបន្តកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរនាថ្ងៃនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការអនុវត្តក្របខណ្ឌនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅឆ្ពោះទៅសម្រេចសេដ្ឋកិច្ចឌីជីថល សង្គមឌីជីថល និងពលរដ្ឋឌីជីថល ដោយផ្តោតលើការអភិវឌ្ឍមូលធនមនុស្សផ្នែកឌីជីថល និងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី លើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុឌីជីថល និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ស្ត្រីនិងគ្រួសារ។

លោកជំទាវកិត្តិបណ្ឌិត ក៏បានមានប្រសាសន៍បន្ថែមទៀតថា៖ "តាមរយៈការអនុវត្តកម្មវិធីនៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការនេះ យើងរកឃើញនិងបង្កើតបាននូវអំណះអំណាងដែលបញ្ជាក់ថា សមត្ថភាពផ្នែកហិរញ្ញវត្ថុនិងឌីជីថល គឺជាឧបករណ៍ដ៏សំខាន់ក្នុងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ច ដល់ស្ត្រី ព្រមទាំងសម្រាប់គ្រួសាររបស់ពួកគេ ហើយស្ត្រីនិងក្មេងស្រី កាន់តែមានលទ្ធភាពប្រសើរជាងមុន ក្នុងការរកប្រាក់ចំណូល។ ភាពអង់អាចផ្នែកសេដ្ឋកិច្ចបានធ្វើឱ្យពួកគេមានឥទ្ធិពលនិងលទ្ធភាពជាវិជ្ជមាន ក្នុងការចូលរួមលើកកម្ពស់សុខុមាលភាពផ្ទាល់ខ្លួន និងជីវភាពរស់នៅរបស់គ្រួសារកាន់តែប្រសើរឡើង»។

គួរំលេចថា មុនពេលចុះអនុស្សរណៈយោគយល់នេះ ធនាគារជាតិនៃកម្ពុជា និង ក្រសួងកិច្ចការនារី បានសហការគ្នារៀបចំវគ្គបណ្តុះបណ្តាលដល់ស្ត្រីសហគ្រិន និស្សិត និងស្ត្រីនៅតាមជនបទ តាមរយៈការចូលរួមសម្របសម្រួលពីពីមន្ទីរកិច្ចការនារី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីគោលដៅ ព្រមទាំងបានរៀបចំវេទិកាជជែកពិភាក្សា និងសិក្ខាសាលាផ្សព្វផ្សាយ ពាក់ព័ន្ធនឹងការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុស្របតាមគោលដៅក្នុងអនុស្សរណៈនៃការយោគយល់ ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងស្ត្រីក្នុងសហគ្រិនភាព" ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។ សមិទ្ធផលទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងសកម្មភាពជំរុញបរិយាបន្នហិរញ្ញវត្ថុ លើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជននៅប្រទេសកម្ពុជា៕

ថ្ងៃ ចន្ទ ៥ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែឧសភា ឆ្នាំ២០២៤

**ទំនាក់ទំនង ៖**

អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦

អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**

www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA